ហើយយោងតាមដេវីឌ ភី.ឆេនឡឺរ៍, តាំងពីដើមឆ្នាំ១៩៧០ សាឡុត-សរបានចេញដំណើរពីកម្ពុជាមកហាណូយ, ទំនងជាសាឡុត-សរបានរួមដំណើរជាមួយ ផាម-វ៉ាន់ដុង ដែលត្រូវបានកោះហៅដោយក្រុងប៉េកាំង, ទើបសាឡុត-សរបានទៅដល់ទីនោះដែរ ។

តាមបញ្ជីខ្មៅ, ម្តងនេះ, សាឡុត-សរមានជោគជ័យក្នុងការបញ្ចុះបញ្ចូលជូ-អេនឡាយ ដែលសីហនុត្រូវជ្រើសយកជាជំហរប្រឆាំងចំពោះលន់-នល់, ហើយដោយហេតុនេះចំពោះសហរដ្ឋអាមេរិកដែរ, ដោយត្រឡប់មករកនយោបាយប្រឆាំងចក្រពត្តិនិយមអាមេរិកាំងវិញ ដែលរូបគាត់បានបោះបង់ចោល កាលពីមួយឆ្នាំមុនដើម្បីដាក់ចំណងទូតជាថ្មីជាមួយអាមេរិក កាលពីខែមេសាឆ្នាំ១៩៦៩ ។

តាមប្រភពផ្សេងទៀត គឺផាម-វ៉ាន់ដុង ដែលបានលើកទឹកចិត្តសីហនុឲ្យតស៊ូដោយសន្យាយកអំណាចឲ្យគាត់វិញ «ក្នុងចន្លោះពេល៤៨ម៉ោង» ។ សំណើដែលសាឡុត-សរបានធ្វើចំពោះជូ-អេនឡាយដូចេ្នះដូចគ្នាបេះបិត ជាមួយដំបូន្មានដែលផាម-វ៉ាន់ដុងបានផ្តល់ទៅសីហនុ ។ ដើម្បីកុំឲ្យសីហនុអាក់អន់ចិត្ត និងដើម្បីការពារអនាគតនៃកុម្មុយនិស្តខ្មែរ, មេដឹកនាំចិននិងយួនបានលាក់វត្តមានរបស់សាឡុត-សរនៅប៉េកាំងនេះ មិនឲ្យលេចឮដល់សីហនុ ដែលគាត់បានដឹងថា សាឡុត-សរជាមេដឹកនាំការប្រយុទ្ធនៅកម្ពុជា តែនៅរយៈពេលច្រើនឆ្នាំក្រោយមក (ដេវីដ ភី.ឆេនឡឺរ៍ «រឿមច្បងប៉ុលពត», ទំព័រ១៨៥) ។

បន្ទាប់ពីការសន្ទនាជាមួយផាម-វ៉ាន់ដុង, សីហនុ«បានសំដែងចេតនាក្នុងការបង្កើតរណសិរ្សរួបរួមរំដោះកម្ពុជា» ។ សីហនុបានប្រកាន់យកកលយុទ្ធដ៏សាមញ្ញបំផុតរបស់បក្សកុម្មុយនិស្តអន្តរជាតិ ៖ កលយុទ្ធនៃ«រណសិរ្ស» ។ ការដណ្តើមយកអំណាចរបស់ពួកកុម្មុយនិស្តប្រព្រឹត្តទៅ, បើដោយផ្ទាល់, តាមអំពើព្រៃផ្សៃ, ឬបើដោយប្រើពេលវេលាយូរអង្វែង, តាមអំពើវិទ្ធង្សនា ដែលត្រូវបានបង្កនិងដឹកនាំដោយអង្គការទាំងឡាយ ដែលប្រមូលផ្តុំគ្នានៅក្រោមការគាំពាររបស់«រណសិរ្ស»មួយ ដើម្បីបិទបាំងសកម្មភាពពិតប្រាកដរបស់បក្សកុម្មុយនិស្ត ដែលបានជ្រៀតចូលទៅក្នុងស្នូលនៃ«រណសិរ្ស» ប៉ុន្តែជាអ្នកកាន់កាប់មុខនាទីក្នុងបញ្ជាការ ។

លុះស្អែកឡើង, ថ្ងៃទី២៣មិនា១៩៧០, សីហនុបានថ្លែងតាមរលកធាតុអាកាសនៃវិទ្យុសម្លេងប៉េកាំង អំពីសេចក្តីប្រកាស៥ចំណុច ដែលនៅក្នុងនោះគាត់បានបញ្ជាក់ពីការរំលាយរដ្ឋាភិបាលភ្នំពេញ, ការអំពាវនាវដល់ជនរួមជាតិ ជាទីស្នេហាទាំងអស់នៅកម្ពុជា ក៏ដូចនៅបរទេស ឲ្យបដិសេធការគោរពចំពោះរដ្ឋាភិបាលនេះ, បានប្រកាសពីការបង្កើតលើកក្រោយ នូវ«រដ្ឋាភិបាលរួបរួមជាតិថ្មីមួយ ព្រមទាំងសភាសំរាប់ពិគ្រោះយោបល់បណ្តោះអាសន្ន», បានគ្រោងបង្កើត «កងទ័ពរំដោះជាតិ»,

ហើយទីបញ្ចប់បានស្នើទៅខ្មែរទាំងអស់ «ដែលរស់នៅក្នុងប្រទេសនិងក្រៅប្រទេ-ស, ព្រះសង្ឃ, គ្រហស្ថ, ទាហាន និងរាស្ត្រសាមញ្ញ, បុរសនិងស្ត្រី» ឲ្យរួបរួមគ្នាដើម្បី«បង្កើតរណសិរ្សរួបរួមមួយ តាមឈ្មោះជាផ្លូវការថា រណសិរ្សរួបរួមជាតិកម្ពុជា » ។

ចំណែកខាងយួនវៀតកុងនិងយួនខាងជើង, ឱកាសល្អបានមកដល់ហើយ។ ដោយគ្មានប្រកាសសង្គ្រាម, កងទ័ពយួនកុម្មុយនិស្តបានចាប់ផ្តើមការវាយប្រហារទៅលើទីតាំងនៃរដ្ឋាភិបាលខ្មែរ តាមតំបន់ជាច្រើន នៅថ្ងៃទី២៩មិនា១៩៧០ ។ កាលបរិច្ឆេទនេះកំណត់នូវការចាប់ផ្តើមនៃសង្គ្រាមខ្មែរ, ជាដំបូងបំផុតគឺ «បន្ទាយសង្កាត់សីករងកំពង់ត្រាច», ឈ្មោះថា«បន្ទាយរាចអ៊ាម» នៅស្រុករមាសហែកក្នុងខេត្តស្វាយរៀង, បានទទួលការវាយប្រហារពីវៀតកុង-យួនខាងជើង និងខ្មែរក្រហមមួយក្តាប់តូច ដែលធ្លាប់បានធ្វើសកម្មភាពនៅក្នុងស្រុកនេះតាំងពីឆ្នាំ១៩៦៨ ។ លុះព្រឹកឡើង, ខ្ញុំបានបានទៅជិតបន្ទាយ ។ ជាលើកទីមួយដែលខ្ញុំបានឃើញ ពួកវៀតកុងពាក់ រូបស្តេចសីហនុ នៅលើអាវ, ពួកគេប្រកាសថា មកជួយស្តេចសីហនុ ហើយខ្ញុំបានឮគេនិយាយពាក្យថា អង្គការ ។ បន្ទាប់មក, ខ្ញុំបានឃើញថា អាណិកជនយួនជាច្រើន ដែលរស់នៅផ្សារកំពង់ត្រាច ដែលមានប្រាក់ចាយវាយដូចក្រដា-ស់ និងជិះទោចក្រយន្តយន្តចុះឡើង តាំងពីច្រើនឆ្នាំមកហើយ សុទ្ធជាភ្នាក់ងាររប-ស់វៀតកុងទាំងអស់ ។ ចំណែកទាហានក្នុងបន្ទាយ មិនបានតតាំងជាមួយយួនវៀតកុងទេ ព្រោះបានដឹងជាមុនថា មិនអាចយកឈ្នះលើវៀតកុងបាន ។ ជនរងគ្រោះដល់ស្លាប់តែម្នាក់គត់នៅក្នុងបន្ទាយនេះ គឺអនុសេនីយឯក សុខ-ជោត ដែលបន្ទាប់មកត្រូវបានដឹកចេញពី«បន្ទាយរាចអ៊ាម» ដោយកងអន្តរាគមន៍មកពីទីរួមខេត្តស្វាយរៀង នៅម៉ោង១៨រសៀល ។

សេចក្តីអំពាវនាវរបស់ស្តេចសីហនុ តាមវិទ្យុប៉េកាំង, កាលណោះបើតាមខ្ញុំគិតប្រហែលពុំសូវមានប្រសិទ្ធិភាពចំពោះខ្មែរអ្នកក្រុងទេ, ប៉ុន្តែបើតាមខ្ញុំឃើញផ្ទាល់មានឥទ្ធិពលចំពោះខ្មែរនៅតាមជនបទ ។ កំហឹងរបស់រាស្ត្រខ្មែរ ចំពោះការទម្លាក់ស្តេចសីហនុពីតំណែង បានជំរុញនិងយុវជនអ្នកស្ម័គ្រចិត្តជាច្រើន ឲ្យចូលក្នុងព្រៃម៉ាគីស៍ ដើម្បីទទួលការហ្វឹកហ្វឺនពីពួកវៀតកុង ។ ប៉ុន្តែ, ខ្មែរមួយភាគបានត្រឡប់មករកគ្រួសារវិញ ដោយមិនអាចទ្រាំទ្របាន ជាមួយការវាយប្រហារពីកងទ័ពអាកាសអាមេរិកាំង នៅតាមព្រំដែនទៅលើជំរុំហ្វឹកហ្វឺន ។

នៅថ្ងៃទី១៤មេសា១៩៧០, ឧត្តមសេនិយលន់-នល់បានប្រកាសថា ៖ «ខ្មែរព្រមទទួលរាល់ជំនួយពីបរទេសដោយឥតលក្ខខណ្ឌ ពីគ្រប់មជ្ឈដ្ឋាន, ដើម្បីមានលទ្ធភាពសំរាប់តស៊ូប្រឆាំងសត្រូវឈ្លានពាន» ។ ក្នុងរយៈពេលជាងមួយខែ កងទ័ពនិង

ប្រជាពលរដ្ឋខ្មែរត្រូវប្រឈមមុខតែឯកឯង ជាមួយកងឯកភាពយួនខាងជើងនិងយៀកកុង ដែលមានអាវុធទំនើបជាង និងការហាត់ហ្វឹកហ្វឺនស្ទាត់ជំនាញជាង ដើម្បីរារាំងការឈ្លានពានមកលើដែនដីខ្មែរ ។ នៅថ្ងៃទី២៣មិនា១៩៧០, ក្រោមបញ្ជាការរបស់ឧត្តមសេនីយ សុស្តែន-ហ្វែរណាង់ដេស៍, កងទ័ពខ្មែរបានដណ្ដើមយកបានទីក្រុងស្នួងមកវិញ ដែលស្ថិតនៅចម្ងាយ៣៣គ.ម.ពីទីក្រុងភ្នំពេញ ហើយបញ្ឈប់ការវាយលុករបស់បច្ចាមិត្រសំដៅរដ្ឋធានី ។

យោងតាម នីកូឡា-ឡាង, ជាអ្នកសង្កេតការណ៍ដ៏អង់អាចនិងសុចរិត, «មានព្រឹត្តិការណ៍គួររំភើបហើយឆោតល្ងង់ នៅក្នុងគណៈកម្មាធិការសំរាប់ទប់ទល់ជាមួយសត្រូវ, ដែលត្រូវបានបង្កើតឡើងតាមគ្រឹះស្ថានសិក្សា, តាមក្រសួងរដ្ឋ, តាមសង្កាត់ជាដើម, ដោយការប្រមូលផ្ដុំនូវយុវជននិងយុវនារី ដែលមានឯកសណ្ឋានចំរុះពណ៌គ្នា ហើយដែលឈរកាន់អាវុធ ដើម្បីយាមនៅខាងក្រោយគំនរបាវខ្សាច់ ។ មានកង្វះការពិសោធន៍ នៅក្នុងសំណាក់នៃយុទ្ធជនចំណូលថ្មីទាំងនេះ ដែលហាត់ហ្វឹកហ្វឺនក្រោយម៉ោងធ្វើការនៅការិយាល័យ តាមសួនច្បារនិងទីលានសាធារណៈនៃក្រុងភ្នំពេញ ។ ប៉ុន្តែគេអាចគិតថា ទាហានជំនាន់ព្រេងនាយ ក៏មានលក្ខណៈឆោតល្ងង់, រទ្បិករទ្បក់, ខ្វះការពិសោធន)ដែរ, ហើយដូចទាហានទាំងនេះ, យុវជននិងយុវនារីខ្មែរបានចូលប្រឡូកដោយទឹកចិត្តរំភើបអង់អាចពិតៗ ក្នុងការប្រយុទ្ធប្រឆាំងសត្រូវ ដែលបណ្ដាលឲ្យបាត់បង់ជីវិតរាប់រយរាប់ពាន់នាក់» ។

ពីថ្ងៃទី២៤ទៅ២៥មេសា១៩៧០, ដោយយកតាមគំនិតចាស់ពីឆ្នាំ១៩៦៥ និងដោយមានការជ្រោមជ្រែងពីប៉េកាំង, សីហនុបានស្នើបើក«សន្និសិទកំពូលរបស់ប្រជាជនឥណ្ឌូចិន» ហើយកិច្ចប្រជុំបានត្រូវកោះហៅតាមការផ្ដួចផ្ដើមរបស់សីហនុ ។ យោងតាមឯកសារនេះ, ប្រជាជនទាំងបីនៃឥណ្ឌូចិនត្រូវបានតំណាងដោយគណៈប្រតិភូបួន ៖ ខាងភាគីខ្មែរ ត្រូវបានដឹកនាំដោយសីហនុ ហើយចូលរួមដោយប៉ែន-នុត, ហួត-សម្បត្តិ, សារិន-ឆាក, ចៅ-សេង, ជួន-មុំ និង រឿង-ម៉ាច ។ ចំណែកខៀវ-សំផន, ហ៊ូ-យន់ និងហ៊ូ-នឹម ពុំបានចូលរួមទេ ។ ខាង«ប្រជាជនឡាវ»មានអង្គម្ចាស់ សុផានុវង្ស ជាប្រធាននៃគណៈកម្មាធិការមជ្ឈឹមរបស់រណសិរ្សស្នេហាជាតិលាវ, ព្រមទាំង ខាមសឹត-កែវឡា, ភូមិ-វង្សវិចិត្រ, ខាមផាយ-បុប្ផា និង អ៊ុំហឿន-ភួនសាវ៉ាត ។ ខាងរណសិរ្សយៀកកុងមាន ង្វៀង-ហ៊ឺ ថ ជាប្រធាន, ព្រមទាំងផិញ-ឌិញថាវ, លោកស្រីង្វៀង-ឌិញជី, ឡេ-ក្វាងចាញ់, ង្វៀង-វ៉ាន់ហៀវ និង យ៉ឺ-ដុងយ៉ាង ។ ខាងភាគីយួនខាងជើង មាននាយករដ្ឋមន្ត្រី ផាម-វ៉ាន់ដុង ជាប្រមុខព្រមទាំង ហ្វាង-កុកវៀត, ហ្វាង-មិញជាន, ង្វៀង-កូថាច់ និងង្វៀង-ធឿង ។

ក្រោយមក, អង្គម្ចាស់ សុផានុវង្ស បានអះអាងដោយផ្ទាល់ខ្លួនអំពីកិច្ចប្រជុំនេះ

នៅក្នុងបទសម្ភាសន៍មួយ ជាមួយអ្នកសារពត៌មានជាតិប៉ូឡូញឈ្មោះ ម៉ូនីកា-វ៉រណៅនស្កា ដែលគាត់បានយកមកចុះផ្សាយក្នុងពត៌មាន ទ្រីប៊ូណាលូឌូ នៅថ្ងៃទី២៣មិថុនា១៩៧០ ។ អង្គម្ចាស់ សុផានុវង្ស បានទទួលស្គាល់ថា កិច្ចប្រជុំនៃគណៈប្រតិភូទាំងបួននេះ ពិតជាបានប្រព្រឹត្តទៅនៅក្រុងកង់តុង ដោយមានវត្តមានពីនាយករដ្ឋមន្ត្រីចិនជូ-អេនឡាយ ព្រមទាំងភរិយាផង ។ ក្នុងពិធីជប់លៀងបិទអង្គប្រជុំនៅថ្ងៃទី២៥មេសា១៩៧០, ជូ-អេនឡាយបានប្រកាសប្រាប់គណៈប្រតិភូទាំងបួនថា ប្រទេសរបស់ពួកគេមានព្រំដែនជាប់ផ្ទាល់ជាមួយចិន, ទុកណាកម្ពុជាពុំមានព្រំដែនត្រង់ណាជាប់ជាមួយចិនក៏ដោយ ហើយថា«ដែនដីចិនដ៏ទូលំទូលាយ ជាបង្អែករឹងប៉ឹងសំរាប់ប្រទេសឥណ្ឌូចិនទាំងបី» ។

នៅក្នុងសង្កថាសំរាប់សម្ពោធពិធី, សីហនុបានសង្កត់ធ្ងន់ទៅលើការគាំទ្រពីចិនប្រជាមានិត ហើយចាត់ទុកថា «ជ័យជំនះរបស់ប្រជាជនឥណ្ឌូចិន ដែលបានគាំទ្រយ៉ាងខ្លាំងក្លាពីមហាប្រជាជនចិន និងពីប្រទេសដទៃទៀតក្នុងពិភពលោក» ជាជោគជ័យដែលទទួលបានរួចស្រេច ។

សេចក្ដីជូនពត៌មានចុងក្រោយបញ្ជាក់ថា ៖ «ការតស៊ូរបស់ប្រជាជនទាំងបី ជាការតស៊ូរួម ហើយប្រជាជននិមួយៗត្រូវជួយគ្នាទៅវិញទៅមក គឺអ្វីដែលបានបើកចំហទ្វារ សំរាប់ឲ្យយៀកកុងនិងយួនខាងជើង ចូលឈ្លានពានកម្ពុជា លាវ ដោយសេរី» ។ ឯកសារអះអាងថា ៖ «ដោយប្រកាន់គំនិតតាមគោលការណ៍ថា ការរំដោះនិងការពារប្រទេសនិមួយៗ ជាភារកិច្ចរបស់ប្រជាជនខ្លួន, ភាគីនានាត្រូវធ្វើតាមរាល់លទ្ធភាពរបស់ខ្លួន ដើម្បីផ្ដល់ការគាំទ្រទៅវិញទៅមក ទៅតាមចំណង់របស់ភាគីជាសាមីខ្លួន ហើយដោយផ្អែកលើការគោរពគ្នាទៅវិញទៅមក» ។

ដោយបញ្ជាក់ពីសាមគ្គីភាពរបស់គណៈប្រតិភូទាំងបី, គណៈប្រតិភូហាណូយបានកំណត់យកលក្ខណៈផ្សេងគ្នាសំខាន់មួយ ។ សេចក្ដីជូនពត៌មានបានបញ្ជាក់ជាចុងក្រោយថា ដោយការយល់ព្រមនិងដោយការគាំទ្រដល់គោលដៅរបស់ភាគីលាវ, ខ្មែរ និងយួនខាងត្បូង, «បញ្ហាស្ដីពីឯករាជភាព, សន្តិភាព, អព្យាក្រឹតភាព, ការហាមឃាត់នូវរាល់វត្តមាននៃពលទាហានឬមូលដ្ឋានយោធាបរទេស នៅលើដែនដី, ការមិនចូលរួមក្នុងសម្ព័ន្ធភាពយោធាណាមួយ», គឺគោលការណ៍ដែលត្រូវចុះលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងនៅក្រុងហ្សឺណែវកាលពីឆ្នាំ១៩៥៤ ស្ដីពីឥណ្ឌូចិន និងក្នុងកិច្ចព្រមព្រៀងនៅឆ្នាំ១៩៦២ ស្ដីពីលាវ, គណៈប្រតិភូហាណូយមិនបានចុះហត្ថលេខា ជាការយល់ព្រមក្នុងកិច្ចប្រជុំទេ ។ ដោយចូលរួមក្នុងពិភពកុម្មុយនិស្ត, គណៈប្រតិភូហាណូយមិនអាចត្រូវចាត់ទុកថា អព្យាក្រឹតទេ គឺដំណោះស្រាយពីបទបញ្ជាក្នុងអង្គប្រជុំ ដែលហាណូយបានបដិសេធជាច្រើនលើក ក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយ

នេះ ។ រយៈពេលជាងមួយឆ្នាំបន្ទាប់មក ពួកមេដឹកនាំនៃសន្និសិទកំពូលឥណ្ឌូចិន មិនបានរួមប្រជុំទៀតទេ, សន្និសិទនៅកង់តុងនេះ ដែលត្រូវបានផ្ដួចផ្ដើមដោយសីហនុ ហើយត្រូវបានបញ្ជាដោយជូ-អេនឡាយ, ទំនងមានឥទ្ធិពលយូរអង្វែង ។

តាមរយៈវិទ្យុសម្លេងប៉េកាំង, សីហនុអំពាវនាវឥតឈប់ឈរចំពោះប្រជាជាតិខ្មែរ, ប៉ុន្តែការអានអត្ថបទទាំងនេះ អាចឲ្យកត់សំគាល់ឃើញ អំពីវិធីនិងសំនៀងដែលប្រែប្រួលខុសទម្លាប់ប្រក្រតីពីគ្រាមុនរបស់សីហនុ ។ ប៉េកាំងពុំមែនមិនដឹងថាការអំពាវនាវរបស់គាត់ គ្មានឥទ្ធិពលខ្លាំងទៅលើប្រជារាស្ត្រខ្មែរទេ, ប៉ុន្តែគេនៅបន្តលើកទឹកចិត្តរបស់សីហនុ ឲ្យប្រកាសជាទៀងទាត់ ព្រោះទាំងនេះរួមចំណែកយ៉ាងសំខាន់ ក្នុងល្បែងនយោបាយចិន ។ មុខងាររបស់សីហនុនៅប៉េកាំង មានលក្ខណៈផ្សេងគ្នាពីបំណាងរបស់គាត់ ។ ទុកជាមានពាក្យទ្រគោះយ៉ាងសាហាវ ដែលគាត់បានប្រកាសតាមវិទ្យុសម្លេងភ្នំពេញនៅឆ្នាំ១៩៦៧ ដើម្បីប្រឆាំងជាមួយអ្នកដឹកនាំនៃបដិវត្តន៍វប្បធម៌ចិន, មានន័យថាម៉ៅ-សេទុង។ លិន-ពាវ ជាដើម, ដល់ឥឡូវ, សីហនុបានមកស្ថិតលើអាសនៈជាផ្លូវការនៃទីលាន ទៀន-អានមិន, ក្បែរគ្នាជាមួយមេដឹកនាំនៃបដិវត្តន៍នេះដដែល ។

ពួកមេដឹកនាំចិនប្រាកដជាមិនទាន់ភ្លេច នូវភាសាផ្ទុយគ្នា រវាងស្ដេចសីហនុនិងពួកគេទេ, ប៉ុន្តែសុទ្ធតែបានយល់ដោយគ្រប់គ្រាន់ ដើម្បីមិនទាញយកឱកាសដែលហុចឲ្យពួកគេ នៅថ្ងៃទី១៩មិនា១៩៧០ ក្នុងពេលសីហនុជាប្រមុខរដ្ឋ ដែលធ្លាក់ពីតំណែង បានមកដល់ទីក្រុងប៉េកាំង ។ ចំពោះប៉េកាំង ជាសារៈសំខាន់មួយដែលសេចក្ដីប្រកាសទាំងឡាយ ស្ដីពីនយោបាយចិនកុម្មុយនិស្ត ត្រូវធ្វើឡើងដោយជនបរទេសម្នាក់, ដោយជនជាតិអាស៊ីម្នាក់ ។

សីហនុ, ដែលត្រូវបានជូនដំណើរនៅពេលនោះ ក្នុងទស្សនកិច្ចជាបន្តបន្ទាប់ពាសពេញប្រទេសចិន, បានទៅទស្សនារហូតដល់កូរ៉េខាងជើង ព្រមទាំងហាណូយផង ។ នៅខែមិនា១៩៧០, សីហនុបានប្រកាសអំពីចំណង់ ដើម្បីធ្វើដំណើរទៅមជ្ឈិមបូព៌ា ហើយទៅយូហ្គោស្លាវីនៅនិទាឃរដូវបន្ទាប់, ប៉ុន្តែដំណើរទាំងនេះ មិនត្រូវបានអនុញ្ញាតពីប៉េកាំងទេ ។ ដោយគាប់ចិត្តឬមិនគាប់ចិត្ត, សីហនុត្រូវរស់នៅជិតបុគ្គលដែលគាត់ហៅថា «មិត្តដ៏ថ្លៃថ្លាបំផុត» ៖ ជូ-អេនឡាយ ។ ទោះជាដោយសារចំណងមិត្តភាពនេះ ដែលមកទល់ថ្ងៃនោះមានចំណាស់២៥ឆ្នាំ ក៏សីហនុប្រាកដជាគ្មានឥទ្ធិពលអ្វីទៅលើនយោបាយនៃប្រទេសចិនទេ ។ សីហនុថ្លែងដោយភាពប្រាកដក្នុងចិត្ត នូវអ្វីដែលគេខ្សឹបដាក់គាត់ ។ សីហនុមិនភ័ន្តច្រឡំទៀតទេ គាត់បានក្លាយជាអ្នកនាំពាក្យរបស់ប៉េកាំង ហើយគាត់ដឹងថាមុខនាទីរបស់គាត់នឹងត្រូវចប់កាលណាចិនកុម្មុយនិស្តចង់សំរេច ។